ក

# មាតិកា

## I.-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៦-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៥៤ ស្តីពី ការដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការស៊ីវិលក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ចំនួន ០២ រូប ៧៣៨៤

០៦-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៥៥ ស្តីពី ការដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការស៊ីវិលក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ចំនួន ០៣ រូប ៧៣៨៦

០៦-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៥៦ ស្តីពី ការលុបឈ្មោះឧត្តមសេនីយ៍ត្រី **ផាន់ សិទ្ធិ** ចេញពីក្របខ័ណ្ឌ នៃកងយោធពលខេមរភូមិន្ទ ៧៣៨៨

០៦-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៥៧ ស្តីពី ការដំឡើងឋានៈស្មើ អគ្គនាយកបន្ថែមលើមុខងារបច្ចុប្បន្ន ជូនជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ០៤ រូប ៧៣៨៩

០៦-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៥៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះឧត្តមវង្សា និង សប្បុរសជន ចំនួន ៧៥ អង្គ/នាក់ ៧៣៩០

០៦-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៥៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ ឧកញ៉ា ចំនួន ០២ រូប ៧៣៩២

០៦-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៦១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ចំពោះ មន្ត្រីរាជការ និង សប្បុរសជន ចំនួន ៣១ រូប ៧៣៩៣

០៦-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៦២ ស្តីពី ការតែងតាំងមន្ត្រីរាជការ ចំនួន ០៤ រូប ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៧៣៩៤

០៧-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៦៣ ស្តីពី ការប្រោសព្រះរាជទាន គោរមងារ លោកព្រឹទ្ធាចារ្យមហាឧបាសក **ហ៊ុន ណាង** ជា អ្នកឧកញ៉ាមហាភក្តីសប្បុរិសភោគាធិបតី **ហ៊ុន ណាង** ៧៣៩៥

០៧-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៦៤ ស្តីពី ការតែងតាំងឯកឧត្តមឧត្តមសេនីយ៍ទោ **ម៉ែន សុផុន** ជា ទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ និង ត្រូវបាន ដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ឯក ជូនឯកឧត្តមឧត្តមសេនីយ៍ទោ **ម៉ែន សុផុន** នាយនគរបាលជាតិជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៧៣៩៦

០៧-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៦៥ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៦ រូប ៧៣៩៧
០៧-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៦៨ ស្តីពី ការតែងតាំងឯកឧត្តម សំ ចន្ទ្រាបុត្រ ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ៧៣៩៨

## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ

០៨-៩-២០១១ -អនុក្រឹត្យលេខ ២០៨ អនក្រ.បក ស្តីពី ការកែសម្រួលលើកំណត់សម្គាល់ ıı នៃ ឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និង ទំនិញជាប់កម្រិតកំណត់ ៧៣៩៩
១២-៩-២០១១ -អនុក្រឹត្យលេខ ២០៩ អនក្រ.បក ស្តីពី ការប្រើប្រាស់គណនីឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈ ៧៤០២
១៤-៩-២០១១ -អនុក្រឹត្យលេខ ២១០ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ៧៤០៤
១៥-៩-២០១១ -អនុក្រឹត្យលេខ ២១១ អនក្រ.បក ស្តីពី ការផ្ទេរគណទានថវិកា ៧៤០៦
១៣-៩-២០១១ -អនុក្រឹត្យលេខ ១០៥៦ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៧៤០៨
១៣-៩-២០១១ -អនុក្រឹត្យលេខ ១០៥៧ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និង តែងតាំងមុខតំណែង នាយនគរបាលជាតិ ៧៤០៩
១៥-៩-២០១១ -អនុក្រឹត្យលេខ ១០៥៨ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៧៤១០
១៥-៩-២០១១ -អនុក្រឹត្យលេខ ១០៥៩ អនក្រ.តត ស្តីពី ការប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ៧៤១១
១៩-៩-២០១១ -អនុក្រឹត្យលេខ ១០៦០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៧៤១៣
១៩-៩-២០១១ -អនុក្រឹត្យលេខ ១០៦១ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិ នាយនគរបាលជាតិ ៧៤១៥
១៩-៩-២០១១ -អនុក្រឹត្យលេខ ១០៦២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៧៤១៦
១៩-៩-២០១១ -អនុក្រឹត្យលេខ ១០៦៣ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៧៤២០
១៩-៩-២០១១ -អនុក្រឹត្យលេខ ១០៦៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៧៤២២
១៩-៩-២០១១ -អនុក្រឹត្យលេខ ១០៦៥ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៧៤២៥
២០-៩-២០១១ -អនុក្រឹត្យលេខ ១០៦៦ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចមន្ត្រីរាជការ ៧៤២៧

## ២-សេចក្តីសំរេច

១៩-៩-២០១១ -សេចក្តីសំរេចលេខ ៥៣ សសរ ស្តីពី ការបង្កើតគណៈកម្មការរៀបចំការប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់ នៃព្រះរាជាណាចក្រថៃ ៧៤២៨

## III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៨-៩-២០១១ -ប្រកាសលេខ ៨១១ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊្វៃប្រឹកស៍ អាត (ខេមបូឌា) បង្កើតរោងចក្រ ផលិតកាបូបគ្រប់ប្រភេទ ៧៤៣២

០៨-៩-២០១១ -ប្រកាសលេខ ៨១២ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ចាង ហៀល (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៧៤៣៦

០៨-៩-២០១១ -ប្រកាសលេខ ៨១៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជីង សៀង អ៊ិនដាស្ទ្រី (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៧៤៤០

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១០-៩-២០១០ -លិខិតបញ្ជាក់លេខ ៤២៩៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ី.គី.អិម ត្រេឌីង** ៧៤៤៤

១០-៩-២០១០ -លិខិតបញ្ជាក់លេខ ៤២៩៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន វ៉ៃហ៊ើរ អ៊ិនដាសស្ទ្រៀល អេស អ៊ី ហ្សេត** ៧៤៤៦

១០-៩-២០១០ -លិខិតបញ្ជាក់លេខ ៤២៩៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អតិថឡន៍ អូរស្វោយ ខូ អិលធីឌី** ៧៤៤៨

១៣-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៣១៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេឌីសាន់** ៧៤៥០

១៣-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៣១៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស ជេ ស៊ី ស៊ី ស៊ុយប្លីធី ខូ អិលធីឌី** ៧៤៥២

១៣-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៣១៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គីម ឌី.ចាយ.អ៊ិនវេសមេន** ៧៤៥៤

១៣-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៣២០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សម្បូរ ថគស៍ អឺលី យៀរ៉ផ្លេហៅស៍ & ផ្លេស្តូល** ៧៤៥៦

១៤-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៣២៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សឡា អេហ្វ្រិខលឃ័រ** ៧៤៥៨

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៥៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរសក្តិជូនមន្ត្រីរាជការស៊ីវិលក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង រៀបចំដែនដីនគរូបនីយកម្ម និងសំណង់៖

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរសក្តិ និងថ្នាក់ចាស់ | ឋានន្តរសក្តិ និងថ្នាក់ដំឡើង |
|---|---|---|---|---|
| ១ | សួន ស៊ីផាត | ប | ពីរមន្ត្រី ថ្នាក់លេខ ៣ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ២:** ត្រូវបានដំឡើងថ្នាក់តាមកម្រិតសញ្ញាប័ត្រជូនមន្ត្រីរាជការស៊ីវិលក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍ ៖

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរសក្តិ និងថ្នាក់ចាស់ | ឋានន្តរសក្តិ និងថ្នាក់ដំឡើង |
|---|---|---|---|---|
| ១ | មាស ប៉ុ | ប | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥ |

**មាត្រា៣:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវ ទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ព្រ.ស. ១១០៩.៤៧១*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១*

លេខ: ៤១៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១១
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៥៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរសក្តិ ជូនមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន ៖

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរសក្តិ និងថ្នាក់ចាស់ | ឋានន្តរសក្តិ និងថ្នាក់ដំឡើង |
|---|---|---|---|---|
| **ក្រសួងអភិវឌ្ឍន៍ជនបទ** | | | | |
| ១ | **សៅ ជីវ័ន្ត** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ២ | **យឹម ដុង** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** | | | | |
| ១ | **[illegible]** | ប | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*នស/រកត. ០៩១១/៩៧២*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១*

លេខ: ៨១៨ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០១១

**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៥៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យលរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យលព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានលុបឈ្មោះ ឧត្តមសេនីយ៍ត្រី ផាន់ សីទ្ធី អត្តលេខ ០០៤៣២១ ចេញពីក្របខ័ណ្ឌនៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១សេ. ១១០៩. ៩៧៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១

[illegible]
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០១១
**អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៥៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ជូនជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ៖

១- ឯកឧត្តម **សេង រតនៈ**

២- ឯកឧត្តម **ឃួង ស្រេង**

៣- ឯកឧត្តម **ឃ្លាំង ហួត**

៤- ឯកឧត្តម **គួច ចំរើន**

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស. ១១០៩.៩៧៤

លេខ: ៥៧៤ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០... ខែ កញ្ញា ឆ្នាំ២០១១
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊យ សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៥៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសប្រទានព្រះរាជទាន

ចំពោះ

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះឧត្តមវង្សា និងសប្បុរសជន ចំនួន ៧៥អង្គ/នាក់ ដែលមានគុណបំណាច់ និងស្នាដៃល្អ ក្នុងការចូលរួមចំណែកជួយឧបត្ថម្ភ និងកសាងសមិទ្ធផលនានា ជូនកងយោធពលខេមរភូមិន្ទ

នូវ

**ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

| | | | | | |
|---|---|---|---|---|---|
| ១- សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី | ទេព | វង្ស | ៩- លោកជំទាវ | សុខ | ហួយ |
| ២- សម្តេចព្រះឧត្តមវង្សា | មួង | រ៉ា | ១០- លោកជំទាវ | ថេរ | សុជាតា |
| ៣- ឯកឧត្តម | ប៊ិច | សុខិន | ១១- លោកជំទាវ | ពឹង | សុភា |
| ៤- ឧត្តមសេនីយ៍ឯក | ព្រហ្ម | ឌិន | ១២- លោកជំទាវ | កែវ | ម៉ាលី |
| ៥- ឧត្តមសេនីយ៍ទោ | ទេព | សំអាន | ១៣- លោក | សួស | ឡា |
| ៦- ឧត្តមសេនីយ៍ត្រី | ម៉ន | សាម៉ុន | ១៤- លោក | សោម | ឆាយា |
| ៧- វរសេនីយ៍ឯក | វ៉ា | ឧត្តម | ១៥- ឯកឧត្តម | លី | ប៊ុនធឿន |
| ៨- លោក | ប៉ុក | សុទ្ធា | | | |

**ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

| | | | | | |
|---|---|---|---|---|---|
| ១- លោកជំទាវ | ជា | សំអាត | ១០- លោក | ខ្វយ | ឈីន |
| ២- ឧកញ៉ា | ឆង | សាវុធ | ១១- លោក | ជា | ស្វៀត |
| ៣- លោក | គង់ | សាង | ១២- លោកស្រី | ហេង | ហុង |
| ៤- លោក | ឌួន | សាង | ១៣- លោក | ហេង | វុទ្ធី |
| ៥- លោក | ឃុន | លាងម៉េង | ១៤- លោក | ថៃ | ដារិទ្ធ |
| ៦- លោក | ឡុង | ឆវិទ្ធ | ១៥- លោក | លី | កងវៃ |
| ៧- លោក | ឃី | សុភី | ១៦- លោក | ក្ងួយ | គីមសាយ |
| ៨- លោក | ខៀ | សុផល | ១៧- លោក | អ៊ុម | មាលីស |
| ៩- លោក | អ៊ិន វ៉ាធវិបុល | | ១៨- លោកស្រី | វ៉ា | ធិមល |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**គ - គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

| | | |
|---|---|---|
| ១- ឧកញ៉ា | ខូវ | គីមបាក់ |
| ២- ឧកញ៉ា | ថៃ | ទីណូ |
| ៣- ឧកញ៉ា | ញ៉ិក | ផន |
| ៤- ឧកញ៉ា | មាស | ហន |
| ៥- ឧកញ៉ា | ភូ | ទុនហេង |
| ៦- ឧកញ៉ា | ហេង | ឡុង |
| ៧- ឧកញ៉ា | មៀង | សុខ |
| ៨- ឯកឧត្តម | ហ៊ី | សោភា |
| ៩- ឯកឧត្តម | ស | ថេង |
| ១០- លោកជំទាវ | លីម | ឈីវហូ |
| ១១- លោក | យ៉ែន | ស្រន់ |
| ១២- លោក | ឡុង | វណ្ណៈ |
| ១៣- លោក | ថាច់ | ច័ន្ទដារា |
| ១៤- ឯកឧត្តម | គី | តិច |
| ១៥- លោក | ហាក់ | ប៊ុនថា |
| ១៦- លោក | ជា | ងួន |
| ១៧- លោក | អ៊ូច | ពិសាល |
| ១៨- លោក | គីម | សុង |
| ១៩- លោកស្រី | អ៊ូ | ធលក្ខណ៍ |
| ២០- លោក | លី | សាវុធ |
| ២១- លោក | ម៉ៅ | ធឿង |
| ២២- លោក | ញុក | ផាក |
| ២៣- លោក | អ៊ុង | តាំងឡៃ |
| ២៤- លោក | សៀក | ស៊ុណាត |
| ២៥- លោក | ឈួរ | ចក់ |
| ២៦- លោក | ហ៊ុយ | ភាវ |
| ២៧- លោក | ហួរ | សៀកផេង |
| ២៨- កញ្ញា | នាង | ណារុំ |
| ២៩- លោកស្រី | ប៉ែត | ច័ន្ទណារ៉ា |
| ៣០- លោក | ចៅ | ម៉ៅមុន្នី |
| ៣១- លោកស្រី | គ្រិច | ស៊ីណែម |
| ៣២- លោកស្រី | ស្ងួត្រ | លី |
| ៣៣- លោក | ស្រី | សំណាង |
| ៣៤- លោក | ង៉ោ | ប៊ុនណា |
| ៣៥- លោក | ម៉ៅ | ឆាង |
| ៣៦- លោក | គង់ | ដារ៉ា |
| ៣៧- លោក | ឃុត | លាន |
| ៣៨- លោក | លី | កងស៊ុន |
| ៣៩- លោក | ខួច | គីម |
| ៤០- លោក | ខួច | ឡូញ |
| ៤១- លោក | អ៊ុង | គង |
| ៤២- លោក | ផេង | រ៉ា |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧ ៩ ស. ១១០៩. ៤៧៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១

លេខ: ៤៧២ច.ល
**ដើម្បីចម្លងចែកជូន**
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០១១
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/ ៩៥៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នត្រ័យ ខេមរជ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

ឧកញ៉ាចំនួន០២រូប ដែលបានខិតខំបំពេញភារកិច្ចជូនជាតិ មាតុភូមិ និងមានស្នាដៃល្អ
ក្នុងការចូលរួមចំណែកជួយឧបត្ថម្ភ និងកសាងសមិទ្ធផលនានា ជូនកងយោធពលខេមរភូមិន្ទ

នូវ

គ្រឿងឥស្សរិយយស **ជាតូបការ** :

- ឧកញ៉ា **ឆូច សឿ**
- ឧកញ៉ា **លី ហួរ**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៩. ១១០៩. ៩៧៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១

លេខ: ៨ ៤៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១១
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**ស៊យ សុខា**

**ព្រះរាជក្រឹត្យ**

នស/រកត/០៩១១/ ៩៦១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រធរាធរាមហាក្សត្រ**
**ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**
**ប្រោសព្រះរាជទាន**

ចំពោះ

មន្ត្រីរាជការ និងសប្បុរសជន ចំនួន ៣១រូប មានគុណបំណាច់ និងស្នាដៃល្អ
ក្នុងការចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល

នូវ

**ក-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម **អ៊ុរ សំអួន**
២-ឧកញ៉ា **កែវ ឡា**
៣-លោកជំទាវ **ហុង សុជាតា សួន សិទ្ធិ**

**ខ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសមៈ នារីរ័ត្ន ថ្នាក់ មហាសេនា :**

១-លោកជំទាវ **មាស ម៉ូរីន**
២-ឯកឧត្តម **យុន ហេង**
៣-លោកជំទាវ **នាយ គីមសុទ្ធី**
៤-ឧកញ៉ា **ឡេង ឫទ្ធី**
៥-លោក **ហួរ សុជាតិ**
៦-លោកស្រី **សិទ្ធិ ច័ន្ទរ៉ានី**
៧-លោកស្រី **ឈុន លក្ខិណា**

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១-ឯកឧត្តម **អន សុផាណារ៉ា**
២- លោកជំទាវ **ស្រី រិទ្ធីយ៉ា**
៣-ឧត្តមសេនីយ៍ត្រី **លី ចន្ទតារ៉ា**
៤-លោក **សេង សុចិន្តា**
៥-លោក **លឹម មុនី**
៦-លោក **ច័ន សុខុន្តា**
៧-លោក **ហុង លីមហ៊ាន់**
៨- លោក **អ៊ុំ សុខា**
៩-លោកស្រី **នាយ គីមសុផាត៍**
១០- លោក **សាមុត ធឿន**
១១-លោក **សិទ្ធិ បញ្ញាឫទ្ធិ**
១២-លោក **ម៉ែន ច័ន្ទតុលា**

**ឃ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :**

១- ឯកឧត្តម **យឹម សំអឿន**
២- លោកជំទាវ **ម៉ី ប៊ុតថិឡា**
៣-ឯកឧត្តម **អ៊ុំ ប៊ុនធឿន**
៤- លោកជំទាវ **ហុង មួយ**
៥-លោក **ជួន ឆារី**
៦- លោកស្រី **ឈុន ច័ន្ទបុណ្ណមី**
៧- លោក **នឹម នីរ៉ាដេត**
៨- លោក **សិទ្ធិ បញ្ញាធុន**
៩- លោក SIMON SEAN

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស. ១១០៩. ៩៧៩

លេខ ... ព.ល
**បានចម្លងចេញពីច្បាប់ដើម**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១១
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៦២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងមន្ត្រីរាជការចំនួន ០៤រូប ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ÷

- ឯកឧត្តម **គឹត សុផា**
- ឯកឧត្តម **សុខ សម្បត្តិ**
- ឯកឧត្តម **សោម សុវណ្ណា**
- ឯកឧត្តម **លី សារេត**

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស. ១១០៩.៤៣៩

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១

លេខៈ ៤៩១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១១
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៦៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ លោកព្រឹទ្ធាចារ្យមហាឧបាសក **ហ៊ុន នាង** បានបរិច្ចាគកម្លាំងកាយ-ចិត្ត និងទ្រព្យធនប្រកបដោយសទ្ធាជ្រះថ្លាដ៏ជ្រាលជ្រៅបំផុត បូជាចំពោះព្រះពុទ្ធសាសនា និងសង្គមជាតិ និងបានជួយកសាងសមិទ្ធផលនានា ជួយឧបត្ថម្ភដល់ជនក្រីក្រគ្មានទីពំនឹងទាំងឡាយ ប្រកបដោយមហាសប្បុរសធម៌មនុស្សធម៌ដ៏ឧត្តុង្គឧត្តម នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ប្រោសព្រះរាជទានគោរមងារ

លោកព្រឹទ្ធាចារ្យមហាឧបាសក ហ៊ុន នាង

ជា

អ្នកឧកញ៉ាមហាភក្តីសប្បុរសមោភាធិបតី ហ៊ុន នាង

ន សីហមុនី

នរោត្តម សីហមុនី

៣រល. ១១០៩. ៩៩០

បានឡូវថាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៦៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងឯកឧត្តមឧត្តមសេនីយ៍ទោ **ម៉ែន សុផុន** អត្តលេខ ០១៣៣៣ ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ២** : ត្រូវបានដំឡើងឋានន្តរស័ក្តិ ថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនឯកឧត្តម ឧត្តមសេនីយ៍ទោ **ម៉ែន សុផុន** អត្តលេខ ០១៣៣៣ នាយនគរបាលជាតិជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុក អនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៧ វស. ១១០៩. ៤៤១

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១១

លេខ:៥២៦ ច.ល

**ដើម្បីចម្លងចែកជូន**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០១១

**[illegible]ទី១រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៦៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

**ក- ថ្នាក់ឧត្តមសេនីយ៍ទោ**

- លោកឧត្តមសេនីយ៍ត្រី **រស់ សារ៉ាន់** អត្តលេខ ០៦២៤

**ខ- ថ្នាក់ឧត្តមសេនីយ៍ត្រី**

| | | | |
|---|---|---|---|
| ១- លោកវរសេនីយ៍ឯក | **កែវ ឫទ្ធី** | អត្តលេខ | ០១៣៥៩ |
| ២- លោកវរសេនីយ៍ឯក | **ជា សុខឃីម** | អត្តលេខ | ០៥០៤០ |
| ៣- លោកវរសេនីយ៍ឯក | **ឡាំ ទិបុល** | អត្តលេខ | ០១៣៦០ |
| ៤- លោកវរសេនីយ៍ឯក | **សៀក ហាក់** | អត្តលេខ | ០៥០៩២ |
| ៥- លោកវរសេនីយ៍ឯក | **ខួន ឧុទ្ធី** | អត្តលេខ | ៣៩១៧៧ ។ |

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុក អនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៦ស. ១១០៩. ៩៩២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១១

លេខៈ ៨៧៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០១១

**អគ្គលេខាធិការរង [illegible] រាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៦៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានត្ថមិជាតិសាសនា រត្នត្តយគ្គិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **រស់ ចន្ត្រាបុត្រ** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ចារស. ១១០៩. ៩៩៥

លេខៈ ៨៤៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០១១

អគ្គលេខាធិការរងនៃទីស្តីការគណៈរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១១

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២០៩.អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលលើកំណត់សម្គាល់ II នៃឧបសម្ព័ន្ធ២**

**នៃអនុក្រឹត្យលេខ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧**

**ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់**

******

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ៩១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

# សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលខ្លឹមសារនៅក្នុងកំណត់សម្គាល់ II នៃឧបសម្ព័ន្ធ២ របស់អនុក្រឹត្យលេខ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ ពី " បញ្ជីនេះមិនអនុវត្តចំពោះការនាំចេញឬនាំចូលដែលគ្មានលក្ខណៈពាណិជ្ជកម្មតាមរូបភាពជាទំនិញគំរូ សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកធ្វើដំណើរ សម្ភារៈផ្លាស់ប្តូរលំនៅឋានឬតាមរូបភាពប្រហាក់ប្រហែល។ ការលើកលែងនេះ មិនអនុវត្តចំពោះមុខទំនិញដែលស្ថិតក្រោមមុខសញ្ញាហាមឃាត់ដាច់ខាតក្នុងការនាំចេញ នាំចូល ឬប្រភេទមានហានិភ័យខ្ពស់ដល់សុវត្ថិភាពសាធារណៈ " ទៅជា " **បញ្ជីនេះមិនអនុវត្តចំពោះការនាំចេញឬនាំចូល ដែលគ្មានលក្ខណៈពាណិជ្ជកម្មតាមរូបភាពជាទំនិញគំរូ សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកធ្វើដំណើរ សម្ភារៈផ្លាស់ប្តូរលំនៅឋានឬករណីតាមរូបភាពប្រហាក់ប្រហែល ព្រមទាំងការនាំចេញមានលក្ខណៈពាណិជ្ជកម្ម នូវផលិតផលដែលផលិតពីឈើ (ឈើដាំក្នុងស្រុក) ឬស្សី ផ្តៅ ដើមត្នោត កក់ ឬរពាក់ ជាស្នាដៃសិប្បករសម្រាប់ប្រើក្នុងលំនៅឋាន វត្ថុតុបតែងលម្អ និងរូបចម្លាក់ផ្សេងៗ ដែលមានកម្រិតខ្នាតតិចជាង៥គីឡូក្រាមក្នុងមួយឯកតា។ ការលើកលែងនេះ មិនអនុវត្តចំពោះទំនិញដែលស្ថិតក្រោមមុខសញ្ញាហាមឃាត់ដាច់ខាតក្នុងការនាំចេញឬនាំចូលឬប្រភេទមានហានិភ័យខ្ពស់ដល់សុវត្ថិភាពសាធារណៈ** " វិញ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍផ្នែកឯកជន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

***កន្លែងទទួល៖***

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*

*-ដូចមាត្រា៣*

*-រាជកិច្ច*

*-ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ២០៩ . អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

១✧៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨
- បានឃើញព្រះរាជក្រមលេខ ១១/នស/រកម/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ រអនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

**មាត្រា ១** អនុញ្ញាតឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រើប្រាស់សាច់ប្រាក់ពីគណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈចំនួន ២០ ២៥០ ០០០ ០០០ រៀល (ម្ភៃពាន់ ពីររយហាសិបលានរៀល) សម្រាប់ឲ្យអគ្គិសនីកម្ពុជាខ្ចីដើម្បីវិនិយោគឆ្នាំ ២០១១ នៃគម្រោងពង្រីកប្រព័ន្ធខ្សែបញ្ជូនរងជនបទ ឆ្នាំ ២០១១-២០១៣។

**មាត្រា ២** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា (ដើម្បីជូនជ្រាប)
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ២១០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែល ប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០៦ /៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- តាមសំណើ របស់សាលារាជធានីភ្នំពេញ

## សម្រេច

**មាត្រា ១ :-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំងដីស្ពានីយ៍ប្រេងឥន្ធនៈសូគីម៉ិច ដែលមានទំហំដី ៤០៣ម៉ែត្រក្រឡា ស្ថិតនៅផ្លូវបំបែកស្ទឹងមានជ័យ ចោមចៅ ចំការដូង ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**មាត្រា ២ :-**

ការលប់ទីតាំងដូចមានចែងក្នុងមាត្រា ១ ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាលារាជធានីភ្នំពេញ។

**មាត្រា ៣ :-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ២១១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧ , ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១១

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៦៩ អនក្រ.បក, ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១១

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១** : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១.៥០០ លានរៀល (មួយពាន់ប្រាំរយលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មក ជំពូក ៦១ (សេវាខាងក្រៅ) ចំនួន ៣៩៤.៨៧៥.០០០ រៀល និងជំពូក ៦២ (សេវាខាង ក្រៅផ្សេងៗ) ចំនួន ១.១០៥.១២៥.០០០ រៀល របស់ក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។

**មាត្រា២**: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ចំណាយក្នុងឆ្នាំ ២០១១ លើការរៀបចំកិច្ចប្រជុំអាស៊ានក្នុងនាមជាម្ចាស់ផ្ទះ ចំនួន ០៤ លើក ។

**មាត្រា៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០៥៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០០៦/៤១៩ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការតែងតាំងអគ្គសវនករ អគ្គសវនកររង នៃអាជ្ញាធរសវនកម្មជាតិ
- តាមសំណើរបស់អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ

## សម្រេច

**មាត្រា ១** : ត្រូវបានប្រគល់ភារកិច្ចជូនលោក **យោក សាវ៉ាន់** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ នៃអាជ្ញាធរសវនកម្មជាតិ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៥៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ត្រី **សុខ លីហួត** អត្តលេខ ០២២២២ ពីអនុប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១០៥៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យ លេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តនីការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

### សម្រេច

**មាត្រា ១** : ត្រូវបានប្រគល់ភារកិច្ចជូន លោក **ហាវ សោភា** ឱ្យបំពេញមុខងារ ជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ក្រសួង បរិស្ថាន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែង ក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
ឯកសារ -កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១០៥៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការប្តូរប្រភេទក្របខណ្ឌមន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខជស/រកត/១២៩៧/២៧៣ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីក្រមការ

-បានឃើញអនុក្រឹត្យលេខ០៤អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-យោងតាមការចាំបាច់

## សម្រេច

**មាត្រា១** : ត្រូវបានប្តូរប្រភេទក្របខណ្ឌតាមមុខតំណែងជូនលោក **ខែម មិនថៃ** ទៅក្នុងឋានន្តរស័ក្តិក្រមការដើមខ្សែ ថ្នាក់លេខ៩ នៃក្របខណ្ឌមន្ត្រីក្រមការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៤៧៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនអស់លោក លោកស្រីមន្ត្រីរាជការស៊ីវិលនៅសាលាស្រុកស្រែអំបិល ខេត្តកោះកុង ១៧ រូប ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចបានល្អប្រសើរ ដូចមានរាយនាមខាងក្រោម :

ក- **មេដាយមាសការងារ :**

| | | |
|---|---|---|
| ១-លោក | **មាស សុជា** | អភិបាលរងស្រុកស្រែអំបិល ខេត្តកោះកុង |
| ២-លោក | **យ៉ង់ យ៉ុន** | អធិការរងនគរបាលស្រុកស្រែអំបិល ខេត្តកោះកុង |
| ៣-លោក | **ឈេង សុវណ្ណដា** | ប្រធានការិយាល័យគណនេយ្យសាលាខេត្តកោះកុង |
| ៤-លោក | **អោយ សុគិរិទ្ធី** | អនុប្រធានការិយាល័យភូមិបាលស្រុកស្រែអំបិល ខេត្តកោះកុង |
| ៥-លោក | **លិន តាំ** | អនុប្រធានការិយាល័យភូមិបាលស្រុកស្រែអំបិល ខេត្តកោះកុង |

ខ- **មេដាយប្រាក់ការងារ :**

| | | |
|---|---|---|
| ១-លោកស្រី | **ទិត សុភាព** | អភិបាលរងស្រុកស្រែអំបិល ខេត្តកោះកុង |
| ២-លោក | **ម៉ៅ សំអាត** | អនុប្រធានការិយាល័យសរុប និងព័ត៌មានសាលាខេត្តកោះកុង |

គ- **មេដាយសំរិទ្ធការងារ :**

| | | |
|---|---|---|
| ១-លោក | **ហុង ប្រុស** | នាយករដ្ឋបាលសាលាស្រុកស្រែអំបិល ខេត្តកោះកុង |
| ២-លោក | **គៀត សារិន** | នាយករងរដ្ឋបាលសាលាស្រុកស្រែអំបិល ខេត្តកោះកុង |
| ៣-លោក | **ទឹម សុខ្ន** | ប្រធានការិយាល័យសាលាស្រុកស្រែអំបិល ខេត្តកោះកុង |
| ៤-លោក | **តេង នាង** | ប្រធានការិយាល័យសាលាស្រុកស្រែអំបិល ខេត្តកោះកុង |
| ៥-លោក | **គ្រួច ច្រាជ្ញ** | សមាជិកក្រុមប្រឹក្សាស្រុកស្រែអំបិល ខេត្តកោះកុង |
| ៦-លោក | **ឈឹម ផាង** | មេឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង |
| ៧-លោក | **ឆាយ ខុន** | មេឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង |
| ៨-លោកស្រី | **គីម ផល្លា** | មេឃុំស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង |
| ៩-លោក | **ម៉េង យុយ** | មេឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង |
| ១០-លោក | **តៅ អ៊ាន់** | មេឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង |

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០៦៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **តាច់ លន** អត្តលេខ ៦៤២៨៤ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០៦២.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូន ជូននាយទាហាន និងនាយទាហានរង ចំនួន ៧៤ រូប ចំណុះយោធភូមិភាគទី ៥ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចការពារបូរណភាពទឹកដី តាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ**

| | | | | | |
|---|---|---|---|---|---|
| ១- | វរសេនីយ៍ឯក | **ជិន** | **ម៉ិនលាង** | ០៦៥១៣២ | នាយរង ការិយាល័យការពារព្រំដែនគោក |
| ២- | វរសេនីយ៍ទោ | **សេង** | **សារិទ្ធ** | ០១២៨២៩ | នាយរងផ្នែក ការិយាល័យការពារព្រំដែនគោក |
| ៣- | វរសេនីយ៍ត្រី | **ហ៊ីន** | **គីមឡេង** | ០២១៨០៨ | នាយរងផ្នែក ការិយាល័យការពារព្រំដែនគោក |
| ៤- | វរសេនីយ៍ត្រី | **រឹម** | **ឆា** | ១៨៧៣៣៧ | នាយរងផ្នែក ការិយាល័យការពារព្រំដែនគោក |
| ៥- | វរសេនីយ៍ត្រី | **ទ៉ាន់** | **សុវឌ្ឍី** | ០៨៩៨២៨ | នាយរងផ្នែក ការិយាល័យការពារព្រំដែនគោក |
| ៦- | វរសេនីយ៍ត្រី | **ស៊ុម** | **សុគន្ធ** | ០២៣០៤៥ | នាយផ្នែកព័ត៌មានការិយាល័យទី២ យោធភូមិភាគទី៥ |
| ៧- | វរសេនីយ៍ត្រី | **ខែ៊ត** | **ធី** | ១៥៥៦៦២ | នាយលេខាធិការដ្ឋាន តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ៨- | វរសេនីយ៍ត្រី | **អ៊ុច** | **ចាន់ថន** | ០១៥៦៥២ | នាយការិយាល័យទី២ តំបន់ប្រតិបត្តិការសឹករងកោះកុង |



18

| | | | | | |
|---|---|---|---|---|---|
| ៩- | វរសេនីយ៍ត្រី | អ៊ុន | ប៊ុនថា | ០១០៥៥៣ | មេបញ្ជាការ ផ្នែកសិករងខេមរភូមិន្ទ តំបន់ប្រតិបត្តិការសិករងកោះកុង |
| ១០- | វរសេនីយ៍ត្រី | អ៊ុន | ចាន់មុណី | ០១៥៦៦៥ | មេបញ្ជាការ ផ្នែកសិករងបូទុមសាគរ តំបន់ប្រតិបត្តិការសិករងកោះកុង |
| ១១- | វរសេនីយ៍ត្រី | កែវ | ថន | ០១៥៦៦៤ | មេបញ្ជាការ ផ្នែកសិករងថ្មបាំង តំបន់ប្រតិបត្តិការសិករងកោះកុង |
| ១២- | វរសេនីយ៍ត្រី | នុត | ណារ៉ា | ០២២៣០៨ | មេបញ្ជាការ ផ្នែកសិករងស្រែអំបិល តំបន់ប្រតិបត្តិការសិករងកោះកុង |
| ១៣- | អនុសេនីយ៍ឯក | ឡឿន | ចន្ធី | ០៣៥៦៣៩ | ជំនួយការ មណ្ឌល៥ ការិយាល័យទី២ |
| ១៤- | អនុសេនីយ៍ឯក | កែវ | ធី | ០១៤៣៨៨ | នាយរងផ្នែក ប្រព័ន្ធច្បាប់ អធិការកិច្ច កងទ័ពជើងគោក |
| ១៥- | អនុសេនីយ៍ឯក | ឡៀង | រិទ្ធា | ០៣៤៩៣៨ | ជំនួយការ ផ្នែកភូមិភាគ អធិការកិច្ច កងទ័ពជើងគោក |
| ១៦- | អនុសេនីយ៍ឯក | ទូច | ទុំទិបុល | ០៣៦៧៩៣ | ជំនួយការ គីមីសាស្ត្រ បញ្ជាការដ្ឋានរថក្រោះ |
| ១៧- | អនុសេនីយ៍ឯក | ឡូ | សិត្ថានិត | ០៧៤៧១៣ | ជំនួយការ ការិយាល័យការពារព្រំដែនគោក |
| ១៨- | អនុសេនីយ៍ឯក | ឈាន | ផុល | ១៤០៨៦២ | ជំនួយការ ការិយាល័យការពារព្រំដែនគោក |
| ១៩- | អនុសេនីយ៍ឯក | ឡៀង | ហួរ | ១៥១២៩៧ | ជំនួយការ ការិយាល័យការពារព្រំដែនគោក |
| ២០- | អនុសេនីយ៍ឯក | ស៊ុន | ម៉ៅ | ០៤២២២៥ | ជំនួយការស្នាក់ការខត្តបន្ទាយមានជ័យ មណ្ឌល៥ ការិយាល័យទី២ |
| ២១- | អនុសេនីយ៍ឯក | ព្រាប | ប៊ុនសេង | ០៤៧៨៩៧ | នាយរងការិយាល័យការពារព្រំដែន យោធភូមិភាគទី៣ |
| ២២- | អនុសេនីយ៍ឯក | ពោ | សារិន | ០១៥៦៦៧ | នាយរងការិយាល័យទី១ តំន់ប្រតិបត្តិការសិករងកោះកុង |
| ២៣- | អនុសេនីយ៍ឯក | អ៊ុន | សារ៉ាយ | ១៥៧៨៨៩ | នាយការិយាល័យទី៣ តំបន់ប្រតិបត្តិការសិករងកោះកុង |
| ២៤- | អនុសេនីយ៍ឯក | កង | សេត | ១៥៨០១០ | នាយការិយាល័យទី៤ តំបន់ប្រតិបត្តិការសិករងកោះកុង |
| ២៥- | អនុសេនីយ៍ឯក | ស្លាន់ | សំបូរ | ០២៩២៩៧ | នាយរងការិយាល័យទី៤ តំបន់ប្រតិបត្តិការសិករងកោះកុង |
| ២៦- | អនុសេនីយ៍ឯក | ពេជ្រ | សាវ៉ាត | ០១៥៦៤៨ | នាយការិយាល័យជីវពល តំបន់ប្រតិបត្តិការសិករងកោះកុង |
| ២៧- | អនុសេនីយ៍ឯក | វៀម | រ៉ែន | ១៥៨០៨៧ | នាយរងការិយាល័យ អភិវឌ្ឍន៍ តំបន់ប្រតិបត្តិការសិករងកោះកុង |
| ២៨- | អនុសេនីយ៍ឯក | នុយ | សុផល | ១៣៨៧៧៩ | នាយរងផ្នែកលេខាធិការដ្ឋាន ការិយាល័យទី២ |
| ២៩- | អនុសេនីយ៍ឯក | ព្រហ្ម | ពុទ្ធិភក្តី | ១៣០៨៣០ | ជំនួយការ ឯកឧត្តម ឧត្តមសេនីយ៍ទោ ព្រហ្ម មរណៈ |
| ៣០- | អនុសេនីយ៍ឯក | ប៉ែន | សុភាព | ០៣១៤៩៧ | នាយផ្នែកសុខាភិបាល តំបន់ប្រតិបត្តិការសិករងកោះកុង |
| ៣១- | អនុសេនីយ៍ឯក | ខាត់ | បេង | ០១០៥៤៩ | មេបញ្ជាការអនុសេនាធំ ការពារអាកាស តំបន់ប្រតិបត្តិការសិករងកោះកុង |
| ៣២- | អនុសេនីយ៍ឯក | ជឹម | សារុំ | ០១៥៦៧២ | មេបញ្ជាការរង ផ្នែកសិករងគិរីសាគរ តំបន់ប្រតិបត្តិការសិករងកោះកុង |
| ៣៣- | អនុសេនីយ៍ឯក | សូ | សាវ៉ាត | ១៥៧៩០៩ | មេបញ្ជាការរង ផ្នែកសិករងមណ្ឌលសីមា តំបន់ប្រតិបត្តិការសិករងកោះកុង |
| ៣៤- | អនុសេនីយ៍ត្រី | ឆង | សុផល | ០៩៣៥៤៣ | មេបញ្ជាការអនុសេនាធំលេខ១វរសេនាតូចលេខ ៣០៣ តំបន់ប្រតិបត្តិការសិករងកោះកុង |

**ខ- មេដាយប្រាក់ការងារ**

| | | | | | |
|---|---|---|---|---|---|
| ១- | វរសេនីយ៍ត្រី | **ខេង** | **សុខុម** | ០១៦៦៩៩ | នាយរងផ្នែក លេខាធិការដ្ឋាន ការិយាល័យទី ៤ |
| ២- | អនុសេនីយ៍ឯក | **សាយ** | **ស៊ីវង៉ាន** | ០៣៦៧៦៣ | ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យទី ១ |
| ៣- | អនុសេនីយ៍ឯក | **ខួន** | **ធឿន** | ១៥៧៩៦៥ | នាយការិយាល័យទី៥ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ៤- | អនុសេនីយ៍ឯក | **អ៊ិន** | **សារិន** | ០២៩២៩៤ | នាយផ្នែកបំភ័ន្ធអក្ខរៈ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ៥- | អនុសេនីយ៍ឯក | **អ៊ុក** | **សំអូន** | ០២៩៣១៥ | នាយផ្នែកបច្ចេកទេស តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ៦- | អនុសេនីយ៍ឯក | **ឈឿង** | **ស្រ៊ិន** | ០២៩៣១៣ | នាយរងការិយាល័យទី៥ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ៧- | អនុសេនីយ៍ឯក | **ជួន** | **សួង** | ០២៩២៩០ | នាយរងការិយាល័យជីវពល តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ៨- | អនុសេនីយ៍ឯក | **ប៉ុក** | **សុខ** | ០២៩២៨១ | នាយរងការិយាល័យហ្វឹកហ្វឺន តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ៩- | អនុសេនីយ៍ឯក | **ប៉ុក** | **ឌុល** | ១៤១២២១ | នាយរងការិយាល័យអភិវឌ្ឍន៍ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ១០- | អនុសេនីយ៍ឯក | **ធី** | **ណៃរាជ** | ០២៩២៩៦ | នាយរងផ្នែកបញ្ជូនសារ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ១១- | អនុសេនីយ៍ឯក | **នឹម** | **ស៊ីវន** | ០១៥៦៦៦ | មេបញ្ជាការរង វរសេនាតូចលេខ១ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ១២- | អនុសេនីយ៍ឯក | **ចក់** | **ចំណាន** | ០២៩៣០១ | មេបញ្ជាការរង វរសេនាតូចលេខ២ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ១៣- | អនុសេនីយ៍ទោ | **គួច** | **សារា** | ១៥៨០២១ | នាយការិយាល័យទី៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ១៤- | អនុសេនីយ៍ទោ | **សុន** | **សេរីហុង** | ០២៩២៨២ | ជំនួយការបុគ្គលិក វរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ១៥- | អនុសេនីយ៍ត្រី | **នាង** | **សារ៉ែត** | ០៥៣៦៧៧ | ជំនួយការ តំបន់ប្រតិបត្តិការសឹករង បន្ទាយមានជ័យ |
| ១៦- | នាយចំណង់ | **ហុក** | **ស៊ីញ៉ា** | ១៣៧៤៦៣ | មេ.រងខ៣ ត១ ផ្នែកសឹករងប៉ោយប៉ែត តំបន់ប្រតិបត្តិការសឹករង បន្ទាយមានជ័យ |
| ១៧- | នាយចំណង់ | **ពៅ** | **សំណាង** | ១៤១២៨៧ | នាយបញ្ជូនសារ តំបន់ប្រតិបត្តិការសឹករងកោះកុង |

**គ-មេដាយសំរឹទ្ធការងារ**

| | | | | | |
|---|---|---|---|---|---|
| ១- | អនុសេនីយ៍ឯក | **សេង** | **សុន** | ០២៩៣១១ | នាយរងការិយាល័យទី៥ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ២- | អនុសេនីយ៍ឯក | **សៅ** | **ចក់** | ០១៩៤៦៩ | នាយរងការិយាល័យហ្វឹកហ្វឺន តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ៣- | អនុសេនីយ៍ឯក | **ណៃ** | **ធិ** | ០៦៥២៧៤ | មេបញ្ជាការរង ផ្នែកសឹករងខេមរភូមិន្ទ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ៤- | អនុសេនីយ៍ឯក | **យ៉ាង** | **រតនៈ** | ១៥៨០០៦ | ជំនួយការភស្តុភារ វរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ៥- | អនុសេនីយ៍ទោ | **ម៉ូ** | **ពឿន** | ១៣៥៦៧៥ | ជំនួយការការិយាល័យ អភិវឌ្ឍន៍ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ៦- | អនុសេនីយ៍ទោ | **ណែម** | **សុគា** | ០៤១៣៣៧ | មេបញ្ជាការរង ការពារអាកាស តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ៧- | អនុសេនីយ៍ទោ | **ភាន់** | **ឆាយ៉ា** | ១៥៧៨៧៨ | ជំនួយការហិរញ្ញវត្ថុ វរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ៨- | អនុសេនីយ៍ត្រី | **សែម** | **អូន** | ២០៧២០៥ | មេបញ្ជាការរង ខ ការពារ វរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |

| | | | | | |
|---|---|---|---|---|---|
| ៩- | នាយចំណង់ | អ៊ុំ | ស៊ីថា | ១៤១១៩១ | មេបញ្ជាការ ខ១ គ១ វរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ១០- | នាយចំណង់ | សែម | មុត | ១៥៨០៣៧ | មេបញ្ជាការរងអនុសេនាធំលេខ៣វរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ១១- | នាយចំណង់ | ញ៉ុច | អឿន | ២០៧៣៤៨ | មេបញ្ជាការ ខ៣ គ១ វរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ១២- | ព្រិន្ទបាលឯក | ថេត | ម៉ិតឈុត | ២០១៦៦៤ | មេក្រុម.រង ផ្នែកសឹករងវ៉េយប៉ែត តំបន់ប្រតិបត្តិការសឹករង បន្ទាយមានជ័យ |
| ១៣- | ព្រិន្ទបាលឯក | ពេជ្រ | ម៉ិនធឿន | ២១៥៦៦២ | នាយទាហានរងស ផ្នែកសឹករងវ៉េយប៉ែត តំបន់ប្រតិបត្តិការសឹករង បន្ទាយមានជ័យ |
| ១៤- | ព្រិន្ទបាលឯក | គីម | ចាន់តារា | ២០៧១៨៧ | មេបញ្ជាការ ខ៣ គ២ វរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ១៥- | ព្រិន្ទបាលឯក | វន | វេន | ១៤១៣០២ | មេបញ្ជាការ ខ១ គ៣ វរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ១៦- | ព្រិន្ទបាលឯក | សាត | វឌ្ឍ | ១៨៧៤២៥ | មេបញ្ជាការ ខ២ គ៣ វរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ១៧- | ព្រិន្ទបាលឯក | សន | សែ | ១៥៧៩៨៨ | មេបញ្ជាការរងខ្សាល់៨២គាំទ្រវរសេនាតូច លេខ៣០៣តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ១៨- | ព្រិន្ទបាលទោ | តិន | សុគន្ធ | ១៤១២៨៤ | ជំនួយការប្រតិបត្តិការ វរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ១៩- | ព្រិន្ទបាលទោ | រិន | សាខន | ០៤៧៣១០ | មេបញ្ជាការរង ខ គ១ វរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ២០- | ព្រិន្ទបាលទោ | តាក់ | ឡាយ | ០៦៥៣០៨ | មេបញ្ជាការរង ខ២ គ១ វរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ២១- | ព្រិន្ទបាលទោ | សែត | ស៊ុន | ១៨៧៤៣៦ | មេបញ្ជាការរង ខ៣ គ២ វរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ២២- | ព្រិន្ទបាលទោ | ស៊ិន | សុផា | ១៣៥៥៧៥ | មេបញ្ជាការខ DKZគាំទ្រវរសេនាតូចលេខ៣០៣ តំបន់ប្រតិបត្តិការសឹករងកោះកុង |
| ២៣- | ពលបាលទោ | ត្រី | សំណាង | ២១៥៦៦១ | យុទ្ធជន ផ្នែកសឹករងវ៉េយប៉ែត តំបន់ប្រតិបត្តិការសឹករង បន្ទាយមានជ័យ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

គណៈរដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:១០៦៣ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូននាយទាហាន និងនាយទាហានរង ឯកទេសសុខាភិបាល ចំណុះយោធភូមិភាគទី ៥ ចំនួន ២៨ រូប ដែលមានស្នាដៃល្អ ក្នុងការជួយព្យាបាលជំងឺ ដល់នាយទាហាន នាយទាហានរង និងពលទាហាន តាមបន្ទាត់ព្រំដែន កម្ពុជា-ថៃ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ**

| | | | | | |
|---|---|---|---|---|---|
| ១- | វរសេនីយ៍ទោ | **ខួន** | **សុភី** | ០១០៦៦៣ | នាយករងមន្ទីរពេទ្យ យោធភូមិភាគទី៥ |
| ២- | វរសេនីយ៍ទោ | **តាន់** | **ខរ៉ោ** | ០១០៦១៥ | នាយរងការិយាល័យហ្វឹកហ្វឺន យោធភូមិភាគទី៥ |
| ៣- | វរសេនីយ៍ទោ | **ដួង** | **សុខសារិន** | ០១០៦២៥ | នាយរងការិយាល័យទី៤ យោធភូមិភាគទី៥ |
| ៤- | វរសេនីយ៍ទោ | **ខែម** | **សារ៉ុម** | ០១០៦៩៤ | នាយរងការិយាល័យ ហិរញ្ញវត្ថុ យោធភូមិភាគទី៥ |
| ៥- | វរសេនីយ៍ត្រី | **ម៉ៅ** | **ឈឿ** | ០១២៩៦២ | នាយរងឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ៦- | វរសេនីយ៍ត្រី | **យូ** | **សុខ** | ០១១៤៩៩ | នាយផ្នែកសិក្សាគំរោង ការិយាល័យទី១ យោធភូមិភាគទី៥ |
| ៧- | វរសេនីយ៍ត្រី | **កែវ** | **តូមិន្ទ** | ០២១៦៧២ | នាយរងផ្នែក បច្ចេកទេស យោធភូមិភាគទី ៥ |

**ខ-មេដាយសុវត្ថារា ថ្នាក់ សេនា**

| | | | | | |
|---|---|---|---|---|---|
| ១- | វរសេនីយ៍ទោ | **គង់** | **សាមិត្ត** | ០១០៥៩៣ | នាយរងលេខាធិការដ្ឋាន យោធភូមិភាគទី ៥ |

| | | | | | |
|---|---|---|---|---|---|
| ២- | វរសេនីយ៍ត្រី | ខា | សំណាង | ០៣០២៥០ | នាយរងឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ៣- | វរសេនីយ៍ត្រី | ឯក | ម៉ុនរី | ០១៥៨៣៨ | នាយរងឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ៤- | វរសេនីយ៍ត្រី | គីម | វណ្ណថា | ០១០៦៧២ | នាយផ្នែករដ្ឋបាលមន្ទីរពេទ្យ យោធភូមិភាគទី៥ |
| ៥- | អនុសេនីយ៍ឯក | ទុយ | សាមុត | ០៤៣២៧៧ | នាយរងឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ៦- | អនុសេនីយ៍ឯក | ពត | សុខុម | ០២៣២៣៩ | មេបញ្ជាការរង វរសេនាតូចការពារអាកាស យោធភូមិភាគទី៥ |
| ៧- | អនុសេនីយ៍ឯក | សំ | សុខុន | ០៥២៤៨២ | បុគ្គលិក វរសេនាតូចការពារអាកាស យោធភូមិភាគទី៥ |

**គ-មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ**

| | | | | | |
|---|---|---|---|---|---|
| ១- | វរសេនីយ៍ទោ | ឈុន | សំបូរ័ត្ន | ០១០៦៧០ | នាយរង ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ២- | វរសេនីយ៍ត្រី | រស់ | សារិទ្ធ | ០១៥៧៨២ | នាយផ្នែកបុគ្គលិក ការិយាល័យទី១ យោធភូមិភាគទី៥ |
| ៣- | វរសេនីយ៍ត្រី | ម៉ុន | សារុន | ០១៩៨៣៣ | នាយអាគារ នាយទាហាន មន្ទីរពេទ្យ យោធភូមិភាគទី៥ |
| ៤- | វរសេនីយ៍ត្រី | ឡុង | ម៉ុនសេង | ០៣០២០៩ | នាយផ្នែកសន្តិសុខ ការិយាល័យទី១ យោធភូមិភាគទី៥ |
| ៥- | អនុសេនីយ៍ឯក | ម៉ុត | ម៉ុនធឿត | ០១៥៨៩២ | ជំនួយការបុគ្គលិកការិយាល័យទី១ យោធភូមិភាគទី៥ |
| ៦- | អនុសេនីយ៍ឯក | សំ | សុវណ្ណា | ០១៥៨៤០ | នាយផ្នែកពិគ្រោះជំងឺ មន្ទីរពេទ្យ យោធភូមិភាគទី៥ |
| ៧- | អនុសេនីយ៍ឯក | ម៉ោល | រួន | ០៣៧១០៣ | នាយអគារ របេង មន្ទីរពេទ្យ យោធភូមិភាគទី៥ |
| ៨- | អនុសេនីយ៍ឯក | សាន់ | ញ៉ឹម | ០៤២០០៨ | នាយរងផ្នែកឱសថ មន្ទីរពេទ្យ យោធភូមិភាគទី៥ |
| ៩- | អនុសេនីយ៍ឯក | រាជ្យ | គង់មុន្នី | ០៦០៧៥៦ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១០- | អនុសេនីយ៍ឯក | ប្រេ | ម្លិះ | ០២១៣៦៦ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១១- | អនុសេនីយ៍ឯក | រស់ | ម៉ុនរ៉ាត់ | ០៧៧១០២ | ជំនួយការ ការិយាល័យហ្វឹកហ្វឺន យោធភូមិភាគទី៥ |
| ១២- | អនុសេនីយ៍ត្រី | យស់ | សាមុត | ០៦២៧២៨ | ជំនួយការ ការិយាល័យហ្វឹកហ្វឺន យោធភូមិភាគទី៥ |
| ១៣- | អនុសេនីយ៍ត្រី | ឆា | សម្ផស្ស | ១៥០៩១៩ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១៤- | នាយចំណង់ | ខ្សែវ | សុណាល | ១១០៧០៨ | ជំនួយការ ការិយាល័យហ្វឹកហ្វឺន យោធភូមិភាគទី៥ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ១០៦៤.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូននាយទាហាននិងនាយទាហានរងឯកទេសសុខាភិបាល ចំនួន ៤៦ រូប ចំណុះយោធភូមិភាគទី ៥ ដែលមានស្នាដៃល្អ ក្នុងការជួយព្យាបាលជំងឺដល់នាយទាហាន នាយទាហានរង និងពលទាហាន តាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ**

| | | | | | |
|---|---|---|---|---|---|
| ១- | វរសេនីយ៍ត្រី | **សិទ្ធ** | **សារាឌុធ** | ០១៤២៩៣ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ២- | អនុសេនីយ៍ឯក | **ចាប់** | **ធី** | ០២៤០៣៤ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ៣- | អនុសេនីយ៍ឯក | **ម៉ី** | **សុភ័ក្តិ** | ០៣៣៨៥៣ | ជំនួយការ ការិយាល័យហ្វឹកហ្វឺន យោធភូមិភាគទី៥ |
| ៤- | អនុសេនីយ៍ឯក | **ណម** | **ប៉ាន់នូ** | ០៣០២៥៣ | នាយរងអាគារ សង្គ្រោះបន្ទាន់ មន្ទីរពេទ្យ យោធភូមិភាគទី៥ |
| ៥- | អនុសេនីយ៍ឯក | **ឈួយ** | **ឆាយ** | ០៣៧៣៨០ | ជំនួយការហិរញ្ញវត្ថុ មន្ទីរពេទ្យយោធភូមិភាគទី៥ |
| ៦- | អនុសេនីយ៍ឯក | **ម៉ិន** | **ច័ន្ទលី** | ២២៧៩១០ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ៧- | អនុសេនីយ៍ឯក | **ចាន់** | **ស៊ីណាត** | ០៨២១៤៧ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |

| | | | | | |
|---|---|---|---|---|---|
| ៨- | អនុសេនីយ៍ទោ | **ដុន** | **ជឿត** | ០៧៣២២៦ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ៩- | អនុសេនីយ៍ទោ | **គិន** | **ចណ្ណា** | ០៧៣៣៧០ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១០- | អនុសេនីយ៍ទោ | **សាយ** | **ស៊ីភារី** | ០៧៦៥៦៦ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១១- | អនុសេនីយ៍ត្រី | **សុផ្លី** | **រតនា** | ១៣១៤៧១ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១២- | នាយចំណង់ | **ចាន់ចន្ធូ** | **ទីវ៉ែន** | ០៧៥៦០៨ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១៣- | ព្រិន្ទបាលឯក | **ទ្រឹង** | **សុខា** | ០៧៣៩៨៩ | បុគ្គលិក ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១៤- | ពលបាលឯក | **ហេង** | **ដារណោ** | ០៨៣៤៣៦ | សិក្ខាកាមពេទ្យ យោធភូមិភាគទី ៥ |

**ខ- មេដាយប្រាក់ការងារ**

| | | | | | |
|---|---|---|---|---|---|
| ១- | អនុសេនីយ៍ឯក | **ស៊ុប** | **ឡឿន** | ០១៥៨៦១ | យោធាចារ្យ សាលាពលទាហានទី៥ |
| ២- | អនុសេនីយ៍ឯក | **ផាន់** | **គឹមសាង** | ០២៤៤៩២ | យោធាចារ្យ សាលាពលទាហានទី៥ |
| ៣- | អនុសេនីយ៍ឯក | **ព្រាប** | **សុជា** | ០១៥៨៤១ | នាយផ្នែកឱសថ មន្ទីរពេទ្យ យោធភូមិភាគទី៥ |
| ៤- | អនុសេនីយ៍ឯក | **ធី** | **ធីមកុមល** | ០៩៥៥៣៨ | នាយអគារ សង្គ្រោះបន្ទាន់ មន្ទីរពេទ្យ យោធភូមិភាគទី៥ |
| ៥- | អនុសេនីយ៍ឯក | **ម៉ៃ** | **យឹមហាន** | ០៣១៥១៨ | នាយរងអគារ នាយទាហាន មន្ទីរពេទ្យ យោធភូមិភាគទី៥ |
| ៦- | អនុសេនីយ៍ឯក | **ពេជ្រ** | **សុផល** | ០៣៧៥៣៨ | នាយរងអគារ សង្គ្រោះបន្ទាន់ មន្ទីរពេទ្យ យោធភូមិភាគទី៥ |
| ៧- | អនុសេនីយ៍ឯក | **សំរិទ្ធ** | **សាវឿង** | ០៨៣៩៩៨ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ៨- | អនុសេនីយ៍ឯក | **ឡៃ** | **សាឡី** | ០១០៦៥៣ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ៩- | អនុសេនីយ៍ទោ | **រតនា** | **សេរី** | ០៣១៤៤៨ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១០- | អនុសេនីយ៍ទោ | **ប៊ុន** | **ផាន្នី** | ០៤៣២៨២ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១១- | អនុសេនីយ៍ទោ | **ប៊ុន** | **ច័ន្ទស្រីលាភ** | ២២៨០១៣ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១២- | អនុសេនីយ៍ទោ | **ហៀក** | **សុខា** | ០៣១៥១៣ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១៣- | អនុសេនីយ៍ទោ | **សឿម** | **សារិទ្ធិ** | ១៨០៦២២ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១៤- | អនុសេនីយ៍ត្រី | **អ៊ូ** | **សុវណ្ណារ៉ា** | ០៥២៦៦១ | នាយផ្នែកមន្ទីរពិសោធន៍ មន្ទីរពេទ្យ យោធភូមិភាគទី៥ |
| ១៥- | អនុសេនីយ៍ត្រី | **លីម** | **សុធា** | ០៤២០៣៦ | យោធាចារ្យ សាលាពលទាហានទី៥ |
| ១៦- | អនុសេនីយ៍ត្រី | **សន** | **សុរិយា** | ១៣២៦៤៦ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១៧- | នាយចំណង់ | **ឡៀម** | **ធី** | ០៨២១៦៤ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១៨- | ព្រិន្ទបាលឯក | **លុង** | **សុខឡូនា** | ០៧៣២៣៦ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |

| | | | | | |
|---|---|---|---|---|---|
| ១៩- | ពលបាលឯក | គូស៊ុំ | សោភា | ០៨៣៤៥៦ | សិក្ខាកាមពេទ្យ យោធភូមិភាគទី ៥ |
| ២០- | ពលបាលឯក | ឃួច | សៅគន្ធ | ១០៩៤៤៦ | សិក្ខាកាមពេទ្យ យោធភូមិភាគទី ៥ |
| ២១- | ពលបាលត្រី | យ៉ុត | សុភាព | ១០៨៨១០ | សិក្ខាកាមពេទ្យ យោធភូមិភាគទី ៥ |

**គ-មេដាយសំរឹទ្ធការងារ**

| | | | | | |
|---|---|---|---|---|---|
| ១- | អនុសេនីយ៍ឯក | ជុំ | ចំរុង | ០១៩៧៤៣ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ២- | អនុសេនីយ៍ទោ | ជា | ច័ន្ទមណ្ណី | ០៤៦៥៤៤ | ជំនួយការ ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ៣- | អនុសេនីយ៍ទោ | ផាត | សាន់ប៉ា | ០៤៦១៩៣ | មេបញ្ជាការ ខ២ គ២ ឃ.វិស្វកម្ម យោធភូមិភាគទី៥ |
| ៤- | អនុសេនីយ៍ទោ | នឹម | ចន្ទ្រា | ០៦១០៥៩ | ជំនួយការ ការិយាល័យទី ២ យោធភូមិភាគទី ៥ |
| ៥- | អនុសេនីយ៍ត្រី | សុខ | ម៉ិប | ០៥២៦៧២ | ជំនួយការរដ្ឋបាល មន្ទីរពេទ្យ យោធភូមិភាគទី៥ |
| ៦- | អនុសេនីយ៍ត្រី | រ័ត្ន | តារើន | ០៥៤០២១ | ជំនួយការឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ៧- | អនុសេនីយ៍ត្រី | លី | សុជាតិ | ០៤៤២៧៩ | ជំនួយការឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ៨- | នាយចំណង់ | ឈឿ | សុភាសិត | ១៣៣០២៩ | ជំនួយការឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ៩- | នាយចំណង់ | លី | សុវណ្ណា | ០៨១៩២៨ | សិក្ខាកាមពេទ្យ យោធភូមិភាគទី ៥ |
| ១០- | ព្រិន្ទបាលឯក | ឌី | ម៉ុនធឿន | ១៣១០៥០ | បុគ្គលិក ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |
| ១១- | ព្រិន្ទបាលឯក | ហាយ | គុណាវ៉ាពីន | ២១៩១៨៨ | បុគ្គលិក ឯកទេសសុខាភិបាល យោធភូមិភាគទី៥ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០១១
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៧៥.អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការពីអនុមន្ត្រី ទៅវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ០១រូប ដូចមានរាយនាមខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១ | **ហេង សិទ្ធី** | ប | ពីអនុមន្ត្រី ថ្នាក់លេខ **១១** | ទៅវរមន្ត្រី ថ្នាក់លេខ **១០** |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា “៣”*
- *រាជកិច្ច*
- *ឯកសារ - កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១០៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ១៤៩ អនក្រ/បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងតាមតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការនៃគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដូចមានរាយនាមខាងក្រោម :

១-លោក **រស់ សាលីន** ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋាន គោលនយោបាយ និង សម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ

២-លោក **អ៊ុល ឈារក់** ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋាន គ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការពហុភាគី និង អន្តរជាតិ

៣-លោក **ផុន សម្ផស្ស** ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានគ្រប់គ្រងព័ត៌មាន និងឯកសារ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការរៀបចំការប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.**

ត្រូវបានបង្កើតគណៈកម្មការរៀបចំការប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រថៃ ដែលមានសមាសភាពដូចខាងក្រោម –

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **អ៊ឹម សិទ្ធី** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | ប្រធាន |
| ២. ឯកឧត្តម | **ជា តាន** | អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | អនុប្រធាន |
| ៣. ឯកឧត្តម | **យូ ស៊ុនឡុង** | អគ្គស្នងការរងនគរបាលជាតិ | អនុប្រធាន |
| ៤. ឯកឧត្តម | **ខួន សារ៉េត** | អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៥. ឯកឧត្តម | **ហ៊ុយ ពិសិដ្ឋ** | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៦. ឯកឧត្តម | **ខេង្ស ពិសេន** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៧. ឯកឧត្តម | **យ៉ា គឹមអ៊ី** | មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ | សមាជិក |

| | | | |
|---|---|---|---|
| ៨. ឯកឧត្តម | **ទូច ណារ៉ុថ** | ស្នងការនគរបាលរាជធានីភ្នំពេញ | សមាជិក |
| ៩. ឯកឧត្តម | **ខៀវ សារ៉ាម៉េត** | នាយខុទ្ទកាល័យនៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១០. លោក | **លី សារ៉ាម៉េត** | នាយករដ្ឋបាលសាលារាជធានីភ្នំពេញ | សមាជិក |
| ១១ លោក | **គល់ សុផាណា** | អគ្គលេខាធិការសហព័ន្ធកីឡាបាល់ទាត់កម្ពុជា | សមាជិក។ |

**ប្រការ ២.**

គណៈកម្មការរៀបចំការប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រថៃ មានភារកិច្ចដូចខាងក្រោម ៖

- ទទួលបន្ទុកដឹកនាំការងាររៀបចំការប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រថៃ នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១១ ឱ្យទទួលបានជោគជ័យ
- រាយការណ៍អំពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ ៣.**

គណៈកម្មការរៀបចំការប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រថៃ មានអនុគណៈកម្មការចំនួន ០៣ ជាសេនាធិការ ដូចខាងក្រោម ៖

- អនុគណៈកម្មការសន្តិសុខ
- អនុគណៈកម្មការពិធីការ
- អនុគណៈកម្មការបច្ចេកទេស។

**ប្រការ ៤.**

អនុគណៈកម្មការសន្តិសុខ មានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **យូ ស៊ុនឡុង** | អគ្គស្នងការរងនគរបាលជាតិ | ប្រធាន |
| ២. ឯកឧត្តម | **ហ៊ីយ ពិសិដ្ឋ** | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៣. ឯកឧត្តម | **ខឡុ ពិសេន** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៤. ឯកឧត្តម | **យ៉ា គឹមអ៊ី** | មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ | សមាជិក |
| ៥. ឯកឧត្តម | **ទូច ណារ៉ុថ** | ស្នងការនគរបាលរាជធានីភ្នំពេញ | សមាជិក។ |

**ប្រការ ៥.**

អនុគណៈកម្មការសន្តិសុខ មានភារកិច្ចដូចខាងក្រោម ៖

- ទទួលបន្ទុករៀបចំ និងធានាសន្តិសុខ សណ្តាប់ធ្នាប់ក្នុងព្រឹត្តិការណ៍ប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រថៃ
- រាយការណ៍អំពីលទ្ធផលការងារជូនគណៈកម្មការរៀបចំការប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រថៃ
- បំពេញភារកិច្ចផ្សេងទៀត ដែលគណៈកម្មការរៀបចំការប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រថៃប្រគល់ជូន។

**ប្រការ ៦.**

អនុគណៈកម្មការពិធីការ មានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១ ឯកឧត្តម | **ជា គាន** | អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិ រៀបចំបុណ្យជាតិ-អន្តរជាតិ | ប្រធាន |
| ២. ឯកឧត្តម | **នួន សារម៉េត** | អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៣. ឯកឧត្តម | **ខៀវ សារម៉េត** | នាយខុទ្ទកាល័យនៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៤. លោក | **លី សារម៉េត** | នាយករដ្ឋបាលសាលារាជធានីភ្នំពេញ | សមាជិក។ |

**ប្រការ ៧.**

អនុគណៈកម្មការពិធីការ មានភារកិច្ចដូចខាងក្រោម ÷

- ជួយសម្របសម្រួលការងាររៀបចំព្រឹត្តិការណ៍ប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រថៃ
- ជួយសម្របសម្រួលក្នុងការរៀបចំគម្រោងចំណាយ និងទទួលខុសត្រូវលើការងារផ្គត់ផ្គង់
- ជួយទំនាក់ទំនងជាមួយភ្នាក់ងារសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីផ្សព្វផ្សាយព្រឹត្តិការណ៍នេះ
- រាយការណ៍អំពីលទ្ធផលការងារជូនគណៈកម្មការរៀបចំការប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រថៃ
- បំពេញភារកិច្ចផ្សេងទៀត ដែលគណៈកម្មការរៀបចំការប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រថៃប្រគល់ជូន។

**ប្រការ ៨.**

អនុគណៈកម្មការបច្ចេកទេស មានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. លោក | **គល់ សុផារណា** | អគ្គលេខាធិការសហព័ន្ធកីឡាបាល់ទាត់កម្ពុជា | ប្រធាន |
| ២. លោក | **ហ៊ុន សាមុត** | ប្រធាននាយកដ្ឋានអប់រំកាយ និងកីឡា នៃក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៣. លោក | **ដួង មាសចំរើន** | ប្រធាននាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស និស្សិត នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៤. លោក | **កែវ សារ៉េត** | អនុប្រធានមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | សមាជិក។ |

**ប្រការ ៩.**

អនុគណៈកម្មការបច្ចេកទេសមានភារកិច្ចដូចខាងក្រោម ÷

- រៀបចំទីលានប្រកួត និងទទួលបន្ទុករៀបចំការហ្វឹកហាត់មុនពេលប្រកួត
- រៀបចំក្រុមអាជ្ញាកណ្តាល និងសម្ភារៈបច្ចេកទេសសម្រាប់បម្រើឱ្យការប្រកួត
- រៀបចំកុមាររើសបាល់ និងកុមារហែចូលទីលានប្រកួត
- កំណត់បទបញ្ជាសម្រាប់ការប្រកួត
- រាយការណ៍អំពីលទ្ធផលការងារជូនគណៈកម្មការរៀបចំការប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រថៃ
- បំពេញភារកិច្ចផ្សេងទៀត ដែលគណៈកម្មការរៀបចំការប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រថៃប្រគល់ជូន។

**ប្រការ ១០.**

គណៈកម្មការរៀបចំការប្រកួតបាល់ទាត់មិត្តភាពអន្តរជាតិ រវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រថៃអាចប្រើប្រាស់មន្ត្រីក្នុងអង្គភាពរបស់ខ្លួនបន្ថែមទៀតាមសំណូមពរ និងទំហំការងារជាក់ស្តែង។

**ប្រការ ១១.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១២.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ប្រការ ៤ ប្រការ ៦ និងប្រការ ៨ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ១២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៨១១...ឧរថ...គន-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ១៨០៨ /១១ គ.វ.ក ចុះថ្ងៃទី០៨.០៨.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហ្វៀប្រ៊ិកស៍ អាត (ខេមបូឌា) ចុះថ្ងៃទី០២.០៨.២០១១

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ហ្វៀប្រ៊ិកស៍ អាត (ខេមបូឌា) តំណាងដោយ លោក Shoichi Aramaki សញ្ជាតិជប៉ុន អាយុ៦៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ MZ0575667 ចុះថ្ងៃទី១៣.១០ ២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន៖ 1-3-17, Jiyugaoka, Meguro-ku, Tokyo, Japan. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Rev.4 Code |
| --- | --- |
| កាបូបគ្រប់ប្រភេទ | ១៥១២ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១. ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone 855-23-211141, Fax : 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" ហ្វេប្រិកស៍ អាត (ខេមបូឌា) "*

*"(FABRIC' S ARTS (CAMBODIA) Co., Ltd. )"*

**ទីតាំងរោងចក្រ ៖** *" ផ្លូវជាតិលេខ៤១ ភូមិព្នៅ ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

